**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ០១៣ សហវ

ថ្ងៃព្រហស្បតិ៍ ៦កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០

# សារាចរណែនាំ

## ស្តីពី

## កិច្ចបញ្ជិកាគណនេយ្យលើការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល

-យោងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៨/៣៤៦ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ស្តីពីគោលការណ៍រួមនៃការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស

-យោងអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

-យោងអនុក្រឹត្យលេខ ១៩១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

-យោងអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការទីភ្នាក់ងារប្រតិបត្តិការពិសេស នៃក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

-យោងប្រកាសអន្តរក្រសួងលេខ ១១៦៨ សនថហ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិការវាងក្រសួងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល

-យោងប្រកាសអន្តរក្រសួងលេខ ៤៧៣ សនថហ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកាអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល

-យោងប្រកាសអន្តរក្រសួងលេខ ១៨២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត

-យោងប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា

-យោងប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

-យោងប្រកាសលេខ ៧៩០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ ស្តីពីការបង្កើតបន្ថែមអនុគណនីនៃមាតិកាថវិកា និងមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ

-យោងប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

-យោងប្រកាសអន្តរក្រសួងលេខ ៦៥៧ សហវ.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៥ ស្តីពីការអនុញ្ញាតឱ្យសេវាសុខាភិបាលអនុវត្តការពិនិត្យ និងព្យាបាលជំងឺដោយយកកម្រៃខ្លះពីអ្នកជំងឺ

-យោងសារាចរលេខ ០០៦ ស្តីពីនីតិវិធី និងកិច្ចបញ្ជិការនៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត

-យោងលិខិតលេខ ៦០០២ សហវ.អថ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ ស្តីពីសំណើរៀបចំអាណាប័កផ្ទេរសិទ្ធិ និងផ្ទេរឥណទានថវិកាពីមន្ទីរសុខាភិបាលរាជធានី ខេត្ត ជូនអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេសទាំង៣៦របស់ក្រសួងសុខាភិបាល។

ដើម្បីមានមូលដ្ឋានសម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យថវិកាថ្នាក់ជាតិ គណនេយ្យថវិការដ្ឋបាលរាជធានី ខេត្ត រជ្ជទេយ្យចំណូល និងរជ្ជទេយ្យបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសារាចរណែនាំអនុវត្ត ដែលមានខ្លឹមសារដូចខាងក្រោម÷

## I.គោលការណ៍រួមនៃការអនុវត្តចំណូល ចំណាយរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត

### ក.រជ្ជទេយ្យចំណូល

១.ចំណូលពីកម្រៃសេវាថែទាំអ្នកជំងឺនៅតាមមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ស្រុក និងមណ្ឌលសុខភាព ដែលប្រមូលបានត្រូវបង់ចំណែក ១% ជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលរាជធានី ខេត្ត។ ចំណូលផ្សេងៗទៀត ក្រៅពីចំណូលកម្រៃសេវាថែទាំអ្នកជំងឺដែលមន្ទីរពេទ្យបង្អែករាជធានី ខេត្ត ស្រុក និងមណ្ឌលសុខភាព ប្រមូលបាន ត្រូវបង់ចំណែក ៧៥% ជាគុណប្រយោជន៍ថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ដោយឡែក ចំពោះចំណូលផ្សេងៗ ដែលប្រមូលតាមរយៈមន្ទីរសុខាភិបាលផ្ទាល់ គឺត្រូវអនុវត្តតាមសារាចរលេខ ០០៦ ស្តីពីនីតិវិធី និងកិច្ចបញ្ជិកានៃការអនុវត្តចំណូលពីកម្រៃសេវារបស់អង្គភាពច្រកចេញតែមួយរាជធានី ខេត្ត និងចំណូលពីកម្រៃសេវា និងចំណូលពីការពិន័យជាប្រាក់ ដែលប្រមូលនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត។

២.រជ្ជទេយ្យករចំណូលនៃថវិការបស់មន្ទីរសុខាភិបាល និងអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស គឺជារជ្ជទេយ្យករចំណូលនៃថវិការបស់អង្គភាពនីមួយៗនោះ។ រជ្ជទេយ្យករចំណូលទាំងនេះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលតាមសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលនៃរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣.នៅពេលដែលរជ្ជទេយ្យករចំណូលរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស បង់ប្រាក់ចូលរតនាគាររាជធានី ខេត្ត គណនេយ្យកររតនាគាររាជធានី ខេត្ត ត្រូវ÷

-កត់ត្រារួមគ្នានូវទឹកប្រាក់ចំណូលក្នុងគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជ

-កត់ត្រាក្នុងគណនីប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២) គណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២) និងគណនីរជ្ជទេយ្យករចំណូល (លេខ ៤៧០៤) រួមគ្នា។

៤.ក្រោយពីបានបង់ប្រាក់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជ រជ្ជទេយ្យករចំណូលនៃថវិការបស់មន្ទីរសុខាភិបាល និងអង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវរៀបចំតារាងរាយលម្អិតអំពីប្រភេទចំណូលថវិកានៃប្រាក់ដែលបានបង់នោះ ទៅតាមគណនី អនុគណនី ដែលពាក់ព័ន្ធ ហើយផ្តល់ជូនទៅរជ្ជទេយ្យករចំណូលនៃថវិការាជធានី ខេត្ត ដើម្បីជាមូលដ្ឋានរៀបចំសលាកបត្របង់ចំណូលថវិកាដោយឡែកៗពីគ្នា។

៥.រជ្ជទេយ្យករចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត រជ្ជទេយ្យករចំណូលរបស់មន្ទីរសុខាភិបាល និងរជ្ជទេយ្យករចំណូលរបស់អង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវកាន់បញ្ជីបេឡា ចុះកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូល និងរៀបចំតារាងតុល្យភាពគណនីរជ្ជទេយ្យចំណូលប្រចាំខែ និងប្រចាំឆ្នាំដោយឡែកពីគ្នា។ នីតិវិធីនៃកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលទាំងបី ត្រូវអនុវត្តតាមសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៨ ស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ខ.ការចំណាយតាមរជ្ជទេយ្យបុរេប្រទាន**

១.ការចំណាយរបស់មន្ទីរសុខាភិបាល តាមនីតិវិធីទូទាត់ត្រង់ នីតិវិធីរជ្ជទេយ្យបុរេប្រទាន និងការបោះផ្សាយអាណត្តិបើកប្រាក់ ជាចំណាយថវិកាដោយប្រើតែអនុគណនី ជំនួយសង្គមផ្សេងៗទៀត (លេខ ៦២០២៨) និងត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុ ជាធរមាន។

២.ការចំណាយរបស់អង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេស តាមរូបភាព÷

-រជ្ជទេយ្យបុរេប្រទាន ដោយបើកផ្តល់ប្រាក់មុនលើកទី១ ស្មើចំនួនទឹកប្រាក់ ១/៤ នៃឥណទានថវិកាប្រចាំឆ្នាំ និងទូទាត់ជាចំណាយថវិកាដោយប្រើឥណទានថវិកាតែអនុគណនី ជំនួយដល់ប្រជាជនសម្រាកពេទ្យ និងចំណាយដំណើរការរបស់មណ្ឌល ថែទាំសុខភាព (លេខ ៦២០២១)។

-ការបោះផ្សាយអាណត្តិបើកប្រាក់ជាចំណាយថវិកាដោយប្រើតែអនុគណនី ជំនួយសង្គមផ្សេងៗទៀត (លេខ ៦២០២៨)។

៣.រជ្ជទេយ្យបុរេប្រទានរបស់អង្គភាពទីភ្នាក់ងារប្រតិបត្តិការពិសេសត្រូវបានបង្កើត ១០០ ភាគរយនៃកញ្ចប់ថវិកាកម្មវិធី។

៤.រដ្ឋបាលរាជធានី ខេត្ត ត្រូវមានតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានថវិកាផ្ទាល់ តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិការបស់មន្ទីរសុខាភិបាល និងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទានសម្រាប់ថវិការបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស ដោយឡែកពីគ្នា។

៥.រជ្ជទេយ្យករបុរេប្រទានរបស់មន្ទីរសុខាភិបាល នៃរដ្ឋបាលរាជធានី ខេត្ត និងអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវតែងតាំងដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់អង្គភាពសាមីតាមរយៈរដ្ឋបាលរាជធានី ខេត្ត។ រជ្ជទេយ្យករបុរេប្រទាន ត្រូវបើកគណនីរជ្ជទេយ្យករបុរេប្រទាននៅរតនាគាររាជធានី ខេត្តរៀងៗខ្លួន។

៦.រជ្ជទេយ្យករបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្ត រជ្ជទេយ្យករបុរេប្រទាន (ថវិការបស់មន្ទីរសុខាភិបាលផ្ទាល់) និងរជ្ជទេយ្យករបុរេប្រទាន (ថវិការបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស) ត្រូវកាន់បញ្ជីបេឡា ចុះកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទាន និងរៀបចំតារាងតុល្យភាពគណនីរជ្ជទេយ្យបុរេប្រទានប្រចាំខែ និងប្រចាំឆ្នាំដោយឡែកពីគ្នា។ នីតិវិធីនៃកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទានទាំង ៣ ផ្នែក ត្រូវអនុវត្តតាមសារាចរណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យរជ្ជទេយ្យបុរេប្រទាន របស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៧.រជ្ជទេយ្យករបុរេប្រទាននៃមន្ទីរសុខាភិបាល និងរជ្ជទេយ្យករបុរេប្រទាននៃអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស ជាអ្នករៀបចំសំណើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទានពីរតនាគាររាជធានី ខេត្តដោយផ្ទាល់។

៨.អាណត្តិនិយ័តកម្មទូទាត់រជ្ជទេយ្យបុរេប្រទាន ត្រូវជម្រះគណនីរជ្ជទេយ្យករបុរេប្រទានរបស់ថវិការដ្ឋបាលរាជធានី ខេត្តផ្ទាល់ គណនីរជ្ជទេយ្យករបុរេប្រទានរបស់ថវិកាមន្ទីរសុខាភិបាល និងគណនីរជ្ជទេយ្យករបុរេប្រទាន នៃអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស ដោយឡែកពីគ្នា។

**គ.គណនេយ្យទូទៅ**

១.គណនេយ្យកររតនាគាររាជធានី ខេត្ត ត្រូវចុះកិច្ចបញ្ជិកា និងតាមដានគណនីរជ្ជទេយ្យករបុរេប្រទាន (លេខ ១៤០២) របស់រដ្ឋបាលរាជធានី ខេត្តផ្ទាល់ គណនីរជ្ជទេយ្យករបុរេប្រទានរបស់មន្ទីរសុខាភិបាល និងគណនីរជ្ជទេយ្យករបុរេប្រទានរបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស។

២.គណនេយ្យកររតនាគាររាជធានី ខេត្ត ត្រូវ÷

-ផ្ទៀងផ្ទាត់តួលេខចលនា និងសមតុល្យនៃគណនីរជ្ជទេយ្យករបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្តផ្ទាល់ (លេខ ១៤០២) ជាមួយចលនា និងសមតុល្យនៃគណនីបុរេប្រទានបានទទួល (លេខ ១១០៨) ដែលកាន់កាប់ដោយរជ្ជទេយ្យករបុរេប្រទានរបស់រដ្ឋបាលរាជធានី ខេត្តផ្ទាល់។

-ផ្ទៀងផ្ទាត់តួលេខចលនា និងសមតុល្យនៃគណនីរជ្ជទេយ្យករបុរេប្រទានរបស់មន្ទីរសុខាភិបាលផ្ទាល់ (លេខ ១៤០២) ជាមួយចលនា និងសមតុល្យនៃគណនីបុរេប្រទានបានទទួល (លេខ ១១០៨) ដែលកាន់កាប់ដោយរជ្ជទេយ្យករបុរេប្រទានរបស់មន្ទីរសុខាភិបាលផ្ទាល់។

-ផ្ទៀងផ្ទាត់តួលេខចលនា និងសមតុល្យនៃគណនីរជ្ជទេយ្យករបុរេប្រទានរបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស (លេខ ១៤០២) ជាមួយចលនា និងសមតុល្យនៃគណនីបុរេប្រទានបានទទួល (លេខ ១១០៨) ដែលកាន់កាប់ដោយរជ្ជទេយ្យករ បុរេប្រទានរបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស។

៣.អាណត្តិនិយ័តកម្ម និងលិខិតយុត្តិការចំណាយថវិកាផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត ចំណាយថវិការបស់មន្ទីរសុខាភិបាលផ្ទាល់ និងចំណាយថវិការបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវបោះផ្សាយដោយឡែកពីគ្នា។

៤.អាណត្តិបើកប្រាក់ចំណាយថវិកាទាំង ៣ ផ្នែក ត្រូវចុះលេខរៀងផ្សេងគ្នា។ នៅលើអាណត្តិនិយ័តកម្មទូទាត់រជ្ជទេយ្យបុរេប្រទានរបស់មន្ទីរសុខាភិបាល និងអាណត្តិនិយ័តកម្មទូទាត់រជ្ជទេយ្យបុរេប្រទានរបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស អត្ថគាហក គឺជារជ្ជទេយ្យករបុរេប្រទានរបស់មន្ទីរសុខាភិបាល ឬ រជ្ជទេយ្យករបុរេប្រទានរបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស។

៥.គណនេយ្យករថវិកាថ្នាក់ជាតិ ត្រូវកត់ត្រាប្រតិបត្តិការចំណូល ចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត នៅក្នុងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត (លេខ ៤៤០២) ជារួម ប៉ុន្តែត្រូវមានការតាមដានបន្ថែមក្នុងប្រព័ន្ធជាប្រអប់ដោយឡែក សម្រាប់ស្ថានភាពចំណូល ចំណាយនៃថវិការបស់រដ្ឋបាលរាជធានី ខេត្តផ្ទាល់ ថវិការបស់មន្ទីរសុខាភិបាលផ្ទាល់ និងអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស។

៦.គណនេយ្យកររដ្ឋបាលរាជធានី ខេត្ត ត្រូវកត់ត្រាប្រតិបត្តិការចំណូល ចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត នៅក្នុងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២) ជារួម។ ប៉ុន្តែ ត្រូវមានការតាមដានក្នុងប្រព័ន្ធដោយឡែកសម្រាប់ស្ថានភាពចំណូល ចំណាយនៃថវិការបស់រដ្ឋបាលរាជធានី ខេត្តផ្ទាល់ ថវិការបស់មន្ទីរសុខាភិបាលផ្ទាល់ និងអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស។

៧.គណនេយ្យករថវិកាថ្នាក់ជាតិ ត្រូវផ្ទៀងផ្ទាត់តួលេខនៃគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត (លេខ ៤៤០២) និងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្តនៅរតនាគារ (លេខ ១២០២) ឱ្យមានសង្គតិភាពគ្នា និងត្រូវបោះពុម្ពបញ្ជីវិភាគគណនីប្រាក់បញ្ញើ

របស់រាជធានី ខេត្ត (លេខ ៤៤០២) ជារួម និងបញ្ជីវិភាគដោយឡែកសម្រាប់ថវិការបស់ផ្នែកនីមួយៗ។

**៨.**ការចំណាយថវិកាផ្ទាល់នៃរដ្ឋបាលរាជធានី ខេត្ត ថវិការបស់មន្ទីរសុខាភិបាល និងថវិការបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវកត់ត្រានៅក្នុងគណនី ឬ អនុគណនី (មាតិកាគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ច) ដូចគ្នា។ ក៏ប៉ុន្តែត្រូវមានការតាមដានលម្អិតបន្ថែមចំណាយថវិការបស់ផ្នែកនីមួយៗ ដើម្បីមានលក្ខណៈងាយស្រួល និងអាចដឹងបាននូវការអនុវត្តចំណូល ចំណាយថវិកាទាំងនេះ ដោយឡែក។

**៩.**ចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិក្នុងការផ្តល់ឧបត្ថម្ភធនជូនរដ្ឋបាលរាជធានី ខេត្ត សម្រាប់អនុវត្តក្នុងក្របខណ្ឌធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ សម្រាប់វិស័យសុខាភិបាល ត្រូវកត់ត្រានៅក្នុងអនុគណនី "**ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ**" (លេខ ៦៥០១៦)។

**១០.**ចំណូលថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលទទួលបានពីឧបត្ថម្ភធនពីថ្នាក់ជាតិ សម្រាប់វិស័យសុខាភិបាលត្រូវកត់ត្រានៅក្នុងអនុគណនី "**ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ**" (លេខ ៧៥០១៦)។

**១១.**ការចំណាយថវិការបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស តាមរជ្ជទេយ្យបុរេប្រទាន ត្រូវកត់ត្រាក្នុងគណនី "**ជំនួយដល់ប្រជាជនសម្រាកពេទ្យនិងចំណាយដំណើរការរបស់មណ្ឌលថែទាំសុខភាព**" (លេខ ៦២០២១) និងចំណាយតាមការទូទាត់ត្រង់ត្រូវកត់ត្រាក្នុងគណនី "**ជំនួយសង្គមផ្សេងទៀត**" (លេខ ៦២០២៨)។

**១២.**នៅដើមឆ្នាំថវិកា ក្នុងករណីចាំបាច់ ហើយគណនីប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត ពុំមានសមតុល្យគ្រប់គ្រាន់សម្រាប់បើកផ្តល់ប្រាក់ចំណាយរបស់មន្ទីរសុខាភិបាល និងអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស យោងតាមផែនការចំណាយប្រចាំត្រីមាសទី១, អាណាប័កផ្ទេរសិទ្ធិ (ប្រធានមន្ទីរសុខាភិបាល និងប្រធានអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស) អាចស្នើសុំរតនាគាររាជធានី ខេត្ត ផ្តល់បុរេប្រទានបំពេញសមតុល្យគណនីប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្តនៅរតនាគារ សម្រាប់ការចំណាយរបស់មន្ទីរសុខាភិបាល និងអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស។

**II.កិច្ចបញ្ជិកាគណនេយ្យទូទៅ**

**១.**យោងតាមផែនការចំណាយប្រចាំត្រីមាសទី១ និងសំណើរបស់អាណាប័កផ្ទេរសិទ្ធិ ស្នើសុំផ្តល់បុរេប្រទាន រតនាគាររាជធានី ខេត្ត ត្រូវកត់ត្រាបំពេញសមតុល្យនៃគណនីប្រាក់បញ្ញើរបស់រដ្ឋបាលរាជធានី ខេត្ត។

ការកត់ត្រាត្រូវអនុវត្តដូចខាងក្រោម៖

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២)។

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិការាជធានី ខេត្ត)**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២)

ឥណទាន គណនី បុរេប្រទានបានទទួល (លេខ ១១០៨)។

**២.**បន្ទាប់ពីគណនីប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត មានសមតុល្យ មន្ទីរសុខាភិបាល និងអង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស អាចស្នើសុំដកប្រាក់រជ្ជទេយ្យបុរេប្រទាន ឬ ទូទាត់ចំណាយតាមតម្រូវការ។

ការកត់ត្រាត្រូវអនុវត្តដូចខាងក្រោម៖

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២)

ឥណទាន គណនី មូលប្បទានបត្រឬបញ្ជាផ្ទេរបានបោះផ្សាយ (លេខ ១១០៧) ឬ

ឥណទាន គណនី ធនាគារ (លេខ ១១២១/១១៣១)។

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិការាជធានី ខេត្ត)**

ឥណពន្ធ គណនី រដ្ឋទេយ្យករបុរេប្រទាន (លេខ ១៤០២) ឬ

ឥណពន្ធ គណនី ត្រូវសង (លេខ ៤...)

ឥណទាន គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២)។

**៣.ការទទួលឧបត្ថម្ភធនរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត**

យោងប្រកាសឥណទានរបស់រតនាគារកណ្តាល ស្តីពីការផ្ទេរឧបត្ថម្ភធនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់អនុវត្តមុខងារសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវកត់ត្រា៖

**-កិច្ចបញ្ជិការបស់រតនាគារកណ្តាល**

ឥណពន្ធ គណនី ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ(លេខ៦៥០១៦)

ឥណទាន ឥណទាយីផ្សេងៗ (លេខ ៤៧០៧៨) **និង**

ឥណពន្ធ គណនី ឥណទាយីផ្សេងៗ (លេខ ៤៧០៧៨)

ឥណទាន គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)។

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២)

ឥណទាន គណនី ប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២)។

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិការាជធានី ខេត្ត)**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២)

ឥណទាន គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ(លេខ ៧៥០១៦)។

**៤.ការទូទាត់ជម្រះប្រាក់បុរេប្រទានដែលមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត បានទទួល**

រតនាគាររាជធានី ខេត្ត ត្រូវជម្រះទូទាត់ដោយស្វ័យប្រវត្តិនូវចំនួនទឹកប្រាក់បុរេប្រទានដែលបានផ្តល់ជូនមន្ទីរសុខាភិបាល (បន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ) និងឧបត្ថម្ភធនដែលបានទទួលពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការកត់ត្រាត្រូវអនុវត្តដូចខាងក្រោម៖

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី ប្រាក់បញ្ញើថវិការបស់រាជធានី ខេត្ត (លេខ ៤៤០២)

ឥណទាន គណនី បុរេប្រទានបន្ថែមសមតុល្យនៃគណនីប្រាក់បញ្ញើ (លេខ ១៥០៥៧)។

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិការាជធានី ខេត្ត)**

ឥណពន្ធ គណនី បុរេប្រទានបានទទួល (លេខ ១១០៨)

ឥណទាន គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្តនៅរតនាគារ (លេខ ១២០២)។

**៥.ការគណនាការអនុវត្តចំណូល ចំណាយថវិកា និងលទ្ធផលនៃកាវិយបរិច្ឆេទរបស់រដ្ឋបាលរាជធានី ខេត្ត**

**៥.១.**មុនពេលបិទបញ្ជីថវិកា និងគណនេយ្យប្រចាំឆ្នាំ គណនេយ្យករថវិការាជធានី ខេត្ត ត្រូវគណនារកតួលេខលម្អៀងរវាងចំណូលថវិកាឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦) និង

សរុបគណនីអនុគណនីចំណាយថវិកាសរុប (ថ្នាក់៦) លើវិស័យសុខាភិបាល (ចំណាយថវិការបស់មន្ទីរសុខាភិបាលផ្ទាល់ និងរបស់អង្គភាពថវិកាទីភ្នាក់ងារប្រតិបត្តិការពិសេស)។

**បញ្ជាក់:** ចំពោះចំណូលថវិកាដែលបានពីសេវាសុខាភិបាល គឺពុំគិតបញ្ចូលក្នុងការគណនាចំនួនទឹកប្រាក់លម្អៀងនៅចំណុច ៥.១ ទេ។

៥.២. បន្ទាប់ពីការគណនាចំនួនទឹកប្រាក់លម្អៀងនៃការអនុវត្តថវិកា (នៅចំណុច ៥.១.) គណនេយ្យករត្រូវកត់ត្រានៅក្នុងគណនេយ្យរដ្ឋ បន្ថយចំនួនទឹកប្រាក់លម្អៀងនោះពីគណនីប្រាក់បញ្ញើថវិការាជធានី ខេត្ត (លេខ ៤៤០២) ជាស្វ័យប្រវត្តិ ដោយផ្ទេរតួលេខដែលបានបន្ថយនោះ តាមរយៈគណនីទំនាក់ទំនងផ្ទេរប្រតិបត្តិការ (លេខ ៤៣០២) ទៅរតនាគារកណ្តាលដើម្បីកត់ត្រាជាសំណែសចំណាយក្នុងឆ្នាំថវិកា។ រីឯកិច្ចបញ្ជិកាគណនេយ្យថវិការាជធានី ខេត្ត ក៏ត្រូវកត់ត្រាបន្ថយពីគណនីចំណូលថវិកាដែលបានពីឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦) និងគណនីប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២) ផងដែរ។

គណនេយ្យករថវិការាជធានី ខេត្ត ត្រូវជូនដំណឹងទៅមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត នូវចំនួនទឹកប្រាក់ដែលបានបន្ថយចំណូលថវិកានោះ។

ការកត់ត្រាត្រូវអនុវត្តដូចខាងក្រោម÷

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិកាថ្នាក់ជាតិ)**

ឥណពន្ធ គណនី បញ្ញើថវិការាជធានី ខេត្ត (លេខ ៤៤០២)

ឥណទាន គណនី ទំនាក់ទំនងប្រតិបត្តិការផ្សេងៗ (លេខ ៤៣០២)។

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិការាជធានី ខេត្ត)**

ឥណពន្ធ គណនី ឧបត្ថម្ភធនពីក្រសួង ស្ថាប័ន សម្រាប់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ (លេខ ៧៥០១៦)

ឥណទាន គណនី ប្រាក់បញ្ញើរបស់រាជធានី ខេត្ត នៅរតនាគារ (លេខ ១២០២)។

**-កិច្ចបញ្ជិការបស់រតនាគារកណ្តាល (ការបង់សំណែសចំណាយ)**

ឥណពន្ធ គណនី ទំនាក់ទំនងប្រតិបត្តិការផ្សេងៗ (លេខ ៤៣០២)

ឥណទាន គណនី ឧបត្ថម្ភធនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ(លេខ ៦៥០១៦)។

៥.៣. គណនេយ្យករនៃថវិការាជធានី ខេត្ត ត្រូវគណនារកអតិរេកថវិកាសរុបរបស់រដ្ឋបាលរាជធានី ខេត្តដោយផ្ទេរសមតុល្យគ្រប់គណនីចំណូលថវិកាទាំងអស់ (គណនីថ្នាក់៧ )និងសមតុល្យគ្រប់គណនីចំណាយថវិកាទាំងអស់ (គណនីថ្នាក់ ៦) ចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ។

ការកត់ត្រាត្រូវអនុវត្តដូចខាងក្រោម÷

**-កិច្ចបញ្ជិការបស់រតនាគាររាជធានី ខេត្ត (គណនេយ្យថវិការាជធានី ខេត្ត)**

ឥណពន្ធ គណនី ចំណូលថវិកា (លេខ ៧...)

ឥណទាន គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ៣២០១) **និង**

ឥណពន្ធ គណនី លទ្ធផលនៃការិយបរិច្ឆេទ (លេខ ៣២០១)

ឥណទាន គណនី ចំណាយថវិកា (៦...)។

**បញ្ជាក់:** សមតុល្យនៃគណនី/អនុគណនីចំណូល ចំណាយថវិការបស់រដ្ឋបាលរាជធានី ខេត្ត ដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទគឺរួមមានទាំងតួលេខចំណូល ចំណាយថវិកាលើវិស័យសុខាភិបាលដែរ។

**៦.ការរៀបចំរបាយការណ៍ចំណូល ចំណាយថវិកា និងរបាយការណ៍លទ្ធផលរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត**

**៦.១.**មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ត្រូវ÷

-រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សមិទ្ធកម្មលើការអនុវត្តមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលក្នុងក្របខណ្ឌថវិកាកម្មវិធីទាំងមូល។

-តាមដាន និងបូកសរុបការអនុវត្តថវិការបស់ខ្លួន រួមទាំងអង្គភាពក្រោមឱវាទដទៃទៀត និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពលើសូចនាករលទ្ធផលក្នុងឆ្នាំជាប្រចាំ។

-ដាក់របាយការណ៍អនុវត្តថវិកាជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពិនិត្យ និងដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត រួចបញ្ជូនមកក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៦.២.**រតនាគាររាជធានី ខេត្ត ត្រូវរៀបចំតារាងតុល្យភាពគណនីប្រចាំខែ ប្រចាំឆ្នាំ និងរបាយការណ៍លទ្ធផលប្រចាំឆ្នាំនៃថវិការាជធានី ខេត្តជារួម របាយការណ៍លទ្ធផលនៃថវិការាជធានី ខេត្តផ្ទាល់ និងរបាយការណ៍លទ្ធផលរបស់មន្ទីរសុខាភិបាលនៃថវិការាជធានី ខេត្ត។

គ្រប់រដ្ឋបាលរាជធានី ខេត្ត មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត រតនាគាររាជធានី ខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវសហការអនុវត្តសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**
- ក្រសួងសុខាភិបាល
- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ
  "ដើម្បីជ្រាប"
- អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ